# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**

**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**


លេខ០៣២៥/០៧ ស.ខ.ក.ក.

## ក្រាបបង្គំទូលថ្វាយ

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់

ទូលព្រះបង្គំជាខ្ញុំម្ចាស់ សេង្វា អតីតសមាជិកព្រឹទ្ធសភា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម និងជាតំណាងអង្គការ-សមាគមខ្មែរកម្ពុជាក្រោម សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈ ទ្រង់ព្រះមេត្តាជ្រាបថា កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៧ មានសង្ឃរាជគណៈដឹកនាំដោយព្រះតេជគុណណយ ច្រឹក, ព្រះតេជគុណឡឹម ហេង និងព្រះតេជគុណឡុង គឹមលាង ចុះទៅចាប់ផ្សឹកព្រះតេជគុណទឹម សាខន ព្រះចៅអធិការវត្តភ្នំដិន ខាងជើង ឃុំភ្នំដិន ស្រុកគីរីវង់ ខេត្ត តាកែវ ដែលមានដើមកំណើតនៅកម្ពុជាក្រោម តាមលិខិតរបស់សម្តេចព្រះសង្ឃនាយកនួន ង៉ែតលេខ៥០២/០៧ ស.ន.ច.ជ. ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៧ ដោយបានចោទប្រកាន់ថា ព្រះតេជគុណទឹម សាខន ថាបានប្រព្រឹត្តខុសនឹងវិន័យព្រះពុទ្ធសាសនា ដែលបានធ្វើឱ្យបែកបាក់សាមគ្គីជាតិ-អន្តរជាតិ ជាពិសេសរវាងប្រទេសទាំងពីរកម្ពុជា-វៀតណាម ដោយយកទីអារាមធ្វើជាទីបញ្ជាការសម្រាប់បំរើចលនាឃោសនាដែលធ្វើឱ្យប៉ះពាល់ដល់វិន័យ និងសេចក្តីថ្លៃថ្នូរព្រះពុទ្ធសាសនា ។

*បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់!*

តាមព្រះវិន័យព្រះពុទ្ធសាសនា ការចាប់ផ្សឹកភិក្ខុសង្ឃអង្គណាមួយបាន លុះត្រាតែព្រះសង្ឃអង្គនោះ បានប្រព្រឹត្តល្មើសក្នុងសិក្ខាបទណាមួយនៃអាបត្តិបារាជិកទាំង៤ ។ ដូចនេះព្រះតេជគុណទឹម សាខន មិនបានប្រព្រឹត្តខុសនឹងព្រះវិន័យក្នុងព្រះពុទ្ធសាសនា ដូចការចោទប្រកាន់ទេ ។ តាមការចុះស្រាវជ្រាវដល់វត្តភ្នំដិនខាងជើងកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ របស់អង្គការ-សមាគមខ្មែរកម្ពុជាក្រោម និងកំណត់ហេតុសមត្ថកិច្ច ដែលចុះឆែកឆេរពុំបានរកឃើញភ័ស្តុតាងអ្វីគួរឱ្យកត់សម្គាល់ថា ព្រះតេជគុណទឹម សាខនអាចធ្វើសកម្មភាពបំបែកបំបាក់មិត្តភាពកម្ពុជា-វៀតណាមបានឡើយ ។ ជាពិសេសព្រះមេគណខេត្តតាកែវ បានមានសង្ឃដីកាប្រាប់អង្គការ-សមាគមខ្មែរកម្ពុជាក្រោម ដែលបានចូលទៅថ្វាយបង្គំព្រះអង្គកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ថាព្រះអង្គពុំបានដឹងថា ព្រះតេជគុណទឹម សាខន បានធ្វើអ្វីខុសទេ ការដែលនាំព្រះតេជគុណទឹម សាខនមកចាប់ផ្សឹកក្នុងវត្តរបស់ព្រះអង្គគ្រាន់តែគេ( សង្ឃរាជគណៈ )ខ្ចីវត្តព្រះអង្គតែប៉ុណ្ណោះ ។

ម្យ៉ាងទៀត តាមសេចក្តីរាយការណ៍របស់កាសែត The Cambodia Daily ចេញផ្សាយថ្ងៃនេះ(០២-០៧-០៧) ដោយស្រង់បន្ទូលសម្តេចព្រះអគ្គមហាសង្ឃាធិបតីទេព វង្សថា *នៅ១១អង្គទៀត ត្រូវចាប់ផ្សឹក ហើយបញ្ជូនឱ្យអាជ្ញាធរយួន*។ តាមសេចក្តីរាយការណ៍របស់កាសែត The Cambodia Daily ថ្ងៃនេះ(០៣-

|


ភូមិគ្រឹះលេខ៥៦ , ផ្លូវ៣៧១ , ភូមិត្រពាំងឈូក , សង្កាត់ទឹកថ្លា , ខណ្ឌឫស្សីកែវ , រាជធានីភ្នំពេញ

ទូរស័ព្ទ-ទូរសារលេខ : (៨៥៥) ២៣ ៩៩៥ ៥៨១, ១២ ៨៥១ ៩៩១ / ៩០ ៨៨ ៨២.

អ៊ីមែល: kkcommunity@camintel.com or k.k.k.c@camitel.com; website: http://khmerkromngo.org

០៧-០៧) ថា ព្រះតេជគុណទឹម សាខន ត្រូវបានអាជ្ញាធរខ្មែរបញ្ជូនទៅឱ្យអាជ្ញាធរវៀតណាមហើយតាមសំណូមពររបស់ព្រះអង្គ ។ ករណីនេះ ទូលព្រះបង្គំយើងខ្ញុំយល់ ឃើញថា មិនពិតទេ ពិព្រោះ:

ទី១-ក្រោយពីការចាប់ផ្សឹកភ្លាម មានជនមិនស្គាល់អត្តសញ្ញាណមួយក្រុមបាននាំខ្លួនព្រះអង្គតាមរថយន្តបញ្ជូនទៅឱ្យអាជ្ញាធរវៀតណាមយ៉ាងតក់ក្រហាលបំផុត តើព្រះអង្គមានពេលឯណាធ្វើលិខិតសំណូមពរមកក្រសួងមហាផ្ទៃសុំឱ្យបញ្ជូនព្រះអង្គទៅប្រទេសវៀតណាម ។

ទី២-ម្តាយឪពុក បងប្អូនរបស់ព្រះតេជគុណ នៅក្បែរវត្តភ្នំដិនទាំងអស់តើព្រះអង្គចង់ទៅប្រទេសវៀតណាមជួបអ្នកណា?

ទី៣-ការចាប់ផ្សឹកបានចោទប្រកាន់ថាព្រះអង្គបានប្រឆាំងអាជ្ញាធរវៀតណាម តើហេតុអ្វីបានជាព្រះអង្គចង់ទៅប្រទេសវៀតណាមឱ្យអាជ្ញាធរវៀត ណាមសម្លាប់ទៅវិញ ។ ដូច្នេះហេតុផលទាំងនេះពុំត្រឹមត្រូវឡើយ ។

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយខាងលើ ទូលព្រះបង្គំយើងខ្ញុំ សូមព្រះបរមរាជានុញ្ញាត ទូលសូមព្រះរាជអន្តរាគមន៏ដ៏ខ្ពង់ខ្ពស់ ពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ទៅរាជរដ្ឋាភិបាលខ្មែរដើម្បីៈ

១- សូមបញ្ជូនព្រះតេជគុណទឹម សាខនត្រឡប់មកកម្ពុជាវិញ

២- បញ្ឈប់ជាបន្ទាន់រាល់ការចាប់ផ្សឹកព្រះសង្ឃខ្មែរកំណើតកម្ពុជាក្រោមជាបន្តទៀត លើកលែងតែត្រូវអាបត្តិបរាជិក ។

៣- បញ្ឈប់រាល់ការគំរាមកំហែងមកលើព្រះសង្ឃខ្មែរកំណើតកម្ពុជាក្រោម និងថ្នាក់ដឹកនាំអង្គការសមាគមខ្មែរកម្ពុជាក្រោម

សូមថ្វាយព្រះពរព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ មានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណវៀងវៃ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជានុរាស្ត្រខ្មែរគ្រប់ទិសទី តរៀងទៅ ។

សេចក្តីពុំគួរ សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ទ្រង់ព្រះរាជទានប្រោស ។

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី០៣ កក្កដា ឆ្នាំ២០០៧*

តំណាងអង្គការ-សមាគមខ្មែរកម្ពុជាក្រោម

**ថាច់ សេដ្ឋា**

អតីតសមាជិកព្រឹទ្ធសភា

ប្រធានសហគមន៏ខ្មែរកម្ពុជាក្រោម